**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ២៩០

ចុះថ្ងៃទី ១១-០៦-២០០៩

សាលដីកា

លេខ : ៥៩ "ខ"

ចុះថ្ងៃទី ២៣-០៧-២០១០

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២៣-០៧-២០១០ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកជំទាវ [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខៈ ២៩០ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ដែលមានៈ

**១- ជនជាប់ចោទឈ្មោះ** [redacted] ពេជ្រ ហៅ និត ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅ [redacted] ទីលំនៅមុនចាប់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយមិនស្គាល់ឈ្មោះ នៅលីវ ទោសពីមុនគ្មាន ត្រូវចាប់ខ្លួនថ្ងៃទី ០៦-០២-២០០៨ ឃុំខ្លួនថ្ងៃទី ២៣-០៤-២០០៨។

មានលោក [redacted]ចន្ថា មេធាវីការពារជនជាប់ចោទ។

**២- ជនជាប់ចោទឈ្មោះ** [redacted] ចាន់ណារី ហៅ [redacted] រ៉ាន់នី ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ មុខរបរលក់កាហ្វេ កើតនៅ [redacted] ទីលំនៅមុនចាប់ខ្លួនផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ ០៥ឆ្នាំ ត្រូវចាប់ខ្លួនថ្ងៃទី ០៦-០២-២០០៨ ឃុំខ្លួនថ្ងៃទី ២៣-០៤-២០០៨។

មានលោក [redacted]ចន្ថា មេធាវីការពារជនជាប់ចោទ។

**ត្រូវជាប់ចោទពីបទៈ** ប្លន់ (គាស់ផ្ទះលួចម៉ូតូ) ប្រព្រឹត្តនៅផ្ទះលេខ ៤៣Z$_{១៣B}$ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ កាលពីថ្ងៃទី ២០ ខែមករា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២១៣

- ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ភេទស្រី អាយុ ៤៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វ [redacted]។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៩១ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] ពេ និងជនជាប់ចោទឈ្មោះ [redacted] វ៉ាន់នី ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៤ "កបIII" ចុះថ្ងៃទី១៨ ខែក ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

## ដំណើររឿងមានដូចតទៅ:

កាលពីថ្ងៃទី ២០ ខែមករា ឆ្នាំ២០០៨ វេលាម៉ោង ១ រំលងអធ្រាត នៅចំណុចផ្ទះលេខ ៤៣Z១៣B ផ្លូវលេខ ៤៦ ក្រុមទី៧៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ មានករណីគាស់ផ្ទះយកម៉ូតូចំនួន ០៤គ្រឿងរបស់ជនរងគ្រោះ ឈ្មោះ [redacted] ចាន់នី ។ នៅថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៨ សមត្ថកិច្ចចាប់បានជនជាប់ចោទឈ្មោះ [redacted] ពេជ្រ ហៅ មិត និ ឈ្មោះ [redacted] ចាន់ណារី ហៅ [redacted] វ៉ាន់នី មកធ្វើការសាកសួរ ហើយជនជាប់ចោទបានឆ្លើយថា ពួកខ្លួនទាំងពីរនាក់ រួមនឹង ឈ្មោះ [redacted] ការម្យ ពិតជាបានធ្វើសកម្មភាពគាស់ផ្ទះជនរងគ្រោះយកម៉ូតូចំនួន ១គ្រឿងមែន ហើយយកទៅលក់ឱ្យ ឈ្មោះ ឆ និងឈ្មោះ ទូច ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៩៤ "កបIII" ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាដំបូ រាជធានីភ្នំពេញ ដែលបានសម្រេចសេចក្តីដូចខាងក្រោម:

១- ផ្តន្ទាទោស:

ក- ឈ្មោះ [redacted] ចាន់ណារី ហៅ [redacted] វ៉ាន់នី ហៅ នី ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់ចំនួ ០៦ ឆ្នាំ ( ប្រាំមួយឆ្នាំ) ។

ខ- ឈ្មោះ [redacted] ពេជ្រ ហៅ សោម ម៉ានិត ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០ ឆ្នាំ ( ប្រាំមួយឆ្នាំ) ។

ពីបទ ប្លន់ (គាស់ផ្ទះលួចម៉ូតូ) ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២០ ខែមករា ឆ្នាំ២០០៨ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២- ទុកសិទ្ធិឱ្យជនរងគ្រោះប្តឹងទាមទារសំណងនៅពេលក្រោយ ។

៣- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៩១ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨ របស់ជនជាប់ចោទឈ្មោះ សំណាង ពេជ្រ និងជនជាប់ចោទឈ្មោះ [redacted] វ៉ាន់នី ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៤ "កបIII" ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## ទាំងលស់ធាតា

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង ២ ២១៤

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ពេជ្រ និងឈ្មោះ [redacted] ចាន់ណារី ហៅ [redacted] រ៉ា បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ ។

ប្រធានក្រុមប្រឹក្សាអានចម្លើយជនរងគ្រោះឈ្មោះ [redacted] ចាន់នី បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ពេជ្រ និងឈ្មោះ [redacted] ចាន់ណារី ពិតជាបានធ្វើសកម្មភាពគាស់ផ្ទះគេយកម៉ូតូបានចំនួន ៤គ្រឿង យកទៅលក់ឱ្យឈ្មោះ ឆយ និងឈ្មោះ ទូច ។ ចម្លើយនេះមានលក្ខណៈស៊ីសង្វាក់នឹងចម្លើយជនរងគ្រោះឈ្មោះ [redacted] ចាន់នី ។ នៅថ្ងៃកើតហេតុពិតជាមានអំពើប្លន់គាស់ផ្ទះលួចយកម៉ូតូប្រាកដមែន ។ ដូចនេះឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់ដូចការចោទប្រកាន់របស់តំណាងអយ្យការមែន ។

ដូច្នេះ តំណាងមហាអយ្យការសាលាឧទ្ធរណ៍សូមសន្និដ្ឋានតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩៤ "កបIII" ចុះថ្ងៃទី ១ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

កូនក្តីពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងមហាអយ្យការមែន ដូច្នេះ សូមប្រធានក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនផង ។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់ ។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍លេខ ៣៩១ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] ពេជ្រ និងឈ្មោះ [redacted] រ៉ាន់ ជាជនជាប់ចោទ ធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។

២- ជនជាប់ចោទបានឆ្លើយសារភាពថា កាលពីថ្ងៃទី ២០ ខែមករា ឆ្នាំ២០០៨ ពួកខ្លួនទាំងពីរនាក់ បានធ្វើសកម្មភាពគាស់ផ្ទះជនរងគ្រោះយកម៉ូតូបានចំនួន ០៤គ្រឿង ។ ក្នុងការធ្វើសកម្មភាពពួកខ្លួនគ្មានអាវុធទេ មានតែឧបករណ៍សម្រាប់គាស់ផ្ទះតែប៉ុណ្ណោះ ។ ម៉ូតូដែលយកបានពួកខ្លួនបានយកទៅលក់ឱ្យ អាឆយ និង អាទូច ដោយ អាកៅ ជាអ្នក លក់ ។ សកម្មភាពនេះ កើតឡើងដោយឈ្មោះ [redacted] ភារម្យ ជាអ្នកបបួល ។

៣- មានពិរុទ្ធលើជនជាប់ចោទ ពីបទ ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២០ ខែមករា ឆ្នាំ២០០៨ តាម មាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ៩៤ "កបIII" ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ ។/២

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៩១ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] រេ
និងឈ្មោះ [redacted] វ៉ាន់ទី ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹង គតិច្បាប់

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩៤ "កបIII" ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាដំ
រាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣- បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១០ ចំពោះមុខមេធាវីការ
ជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៣ ខែក
ឆ្នាំ២០១០ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សាលដីកានេះចូលជាស្ថាពរ មានអានុភាពអនុវត្តតែលើឈ្មោះ [redacted] ពេជ្រ ហៅ និត ក្រៅពីនេះ
ពុំមានអានុភាពអនុវត្តឡើយ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់ម
មន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និ
កងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបា
សម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted] [redacted] | [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]